University of Central Lancashire
សាលា ភាសា អក្សរសាស្ត្រ និង ការសិក្សាអន្តរជាតិ
សាស្ត្រាចារ្យ Ulrike Zeshan MA PhD
នាយក វិទ្យាស្ថានភាសាសញ្ញា និង ការសិក្សាមនុស្សថ្លង់អន្តរជាតិ
សាកលវិទ្យាល័យ Lancashire  Preston PR1  2HE
ទូរស័ព្ទ: (ការិយាល័យ) ០១៧៧២ ៨៩៣១០៤
អ៊ីម៉ែល: uzeshan@uclan.ac.uk
www.uclan.ac.uk/islands

ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៤

ជូនចំពោះអ្នកដែលពាក់ព័ន្ធ

វិទ្យាស្ថាន ភាសាសញ្ញា និង ការសិក្សាមនុស្សថ្លង់ អន្តរជាតិ(iSLanDS)សូមអញ្ជើញអ្នកប្រើសញ្ញា មនុស្សថ្លង់មកពីប្រទេសកម្ពុជា ដើម្បីចូលរួមគំរោងស្រាវជ្រាវ អ្នកប្រើភាសាសញ្ញាអាចប្រើពហុសញ្ញា (ការប្រើធម្មពហុសញ្ញា ត្រូវបានផ្តល់មូលនិក្រុមប្រឹក្សាស្រាវជ្រាវនៅអឺរ៉ុប ។(គំរោងនេះរួមបញ្ចូល ការស្រាវជ្រាវ ការធ្វើសញ្ញាឆ្លងកាត់ប្រទេសផ្សេងៗគ្នា ដែលផ្តោតទៅលើអ្នកប្រើភាសាសញ្ញាផ្សេងៗគ្នាក្នុងការ ទំនាក់ទំនងគ្នាទៅវិញទៅមក។

ពួកយើងបានប្រមូលទិន្នន័យដំបូងនៃការធ្វើសញ្ញាឆ្លងកាត់ប្រទេសផ្សេងៗគ្នានៅចក្រភពអង់គ្លេស នៅឆ្នាំ២០១២។ ពួកគេបានថតខ្សែភាពយន្តពី អ្នកប្រើភាសាសញ្ញាឥណ្ឌូនេស៊ី អ្នកប្រើភាសាសញ្ញាជប៉ុន អ្នកប្រើភាសាសញ្ញាស៊ូតង់ អ្នកប្រើភាសាសញ្ញាអង់គ្លេស។ ឥឡូវនេះ
ពួកយើងចង់ថតខ្សែភាពយន្តអ្នកប្រើភាសាសញ្ញាផ្សេងៗគ្នា។ ពួកយើងមានចិត្តសប្បាយរីករាយពីវត្តមានអ្នកដែលនៅក្នុងសហគមន៍មនុស្សថ្លង់កម្ពុជាដែលអាចប្រើភាសាសញ្ញាកម្ពុជាយ៉ាងស្ទាត់ជំនាញ។ សមាជិកម្នាក់នៅក្នុងគំរោង អ្នកស្រី ថេស៊ី ប្រេដហ្វដ មានបទពិសោធន៍ច្រើនឆ្នាំធ្វើការជាមួយអ្នកប្រើភាសាសញ្ញាកម្ពុជា។ នាងនឹង liaise ជាមួយអ្នកថ្លង់កម្ពុជា ជាមួយនិង ក្រុមអ្នកប្រើពហុសញ្ញា។

ខ្សែភាគយន្តនេះនឹងចំនាយពេល៦សប្តាហ៍នៅវិទ្យាស្ថានដៃគូរបស់យើងនៅប្រទេសឥណ្ឌា
សាកលវិទ្យាសាគុនថាឡាមីសរ៉ា (DSMU) ទីក្រុងឡាក់នាវ  ក្នុងខែ វិច្ឆិកា ដល់ ធ្នូ ឆ្នាំ ២០១៤។

អ្នកចូលរួមមនុស្សថ្លង់របស់យើងគឺពិតជាមានគុណតំលៃណាស់។ ពួកយើងប្រាកដថាអ្នកថ្លង់ត្រូវបាន
ចូលរួមយ៉ាងពេញទំហឹង ដែល........និង បោះបង់ការសិក្សាគ្រប់ពេលវេលា។ ពួកយើងចង់អោយអ្នកចូលរួម
ព្រមទាំង សហគមន៍មនុស្សថ្លង់ របស់ពួកគេ ទទួលបានផលប្រយោជន៍ពីការស្រាវជាវនេះ
ដូច្នេះពួកយើងនឹងធ្វើការបណ្តុះបណ្តាលដល់អ្នកចូលរួមក្នុងកំឡុងពេល៦សប្តាហ៍នេះក្នុងការmetalinguistic
និង ភាពជាអ្នកដឹកនាំសហគមន៍។ ពួកយើងនឹងផ្តល់ឱកាសអោយពួកគាត់ជួបពិភាក្សាជាមួយ
អ្នកប្រើសញ្ញាផ្សេងៗទៀតដែលមកពីគ្រប់ប្រទេសនៅសកលលោក ដូច្នេះ ពួកគាត់អាចសិក្សាពីវប្បធម៌
ផ្សេងៗគ្នា សក្តានុពលមនុស្សថ្លង់ ព្រមសហគមន៍មនុស្សថ្លង់អន្តរជាតិ។ កម្មវិធីអភិវឌ្ឍន៍មនុស្សថ្លង់ (ឌី ឌី ភី)
នៅប្រទេសកម្ពុជានឹងជួយណែនាំ នឹងបញ្ជាក់ពីពួកយើងអោយកាន់តែច្បាស់ពីគុណប្រយោជន៍
នៃការស្រាវជ្រាវជូនសហគមន៍មនុស្សថ្លង់កម្ពុជា។ ពួកយើងចង់បង្កើតភាពជាដៃគូក្នុងការងារពេលខាងមុខ។
ខ្ញុំបានផ្ញើរទំរង់ឯកសារដើម្បីប្រមូលទិន្នន័យ ព្រមទាំងការបកប្រែទំរង់ឯកសារនេះជាភាសាសញ្ញាកម្ពុជា
ដោយអ្នកស្រី ថេស៊ី ប្រេដហ្វដ ជាវីដេអូ។ ពត៌មានលំអិតពីការងាររបស់យើងតាមរយៈ
http://islandscentre.wordpress.com/
http://www.uclan.ac.uk/research/explore/projects/multilingual behaviours sign language users.php

វិទ្យាស្ថាន iSLanDS នឹងផ្តល់សំបុត្រ Visa ផ្លូវការ ជូនអ្នកចូលរួមដែលត្រូវបានជ្រើសរើស។ ពួកយើង
បានធ្វើការច្រើនឆ្នាំជាមួយការស្រាវជ្រាវបេក្ខភាពមនុស្សថ្លង់ ហើយប្រាកដថាពួកគាត់មានសុវត្ថិភាព និង
សប្បាយរីករាយ ដែលទទួលបានការសិក្សា និង បទពិសោធន៍ពីពួកយើង។ ពួកយើងពុំអាចដំណើរ
គំរោងនេះដោយពុំមានជំនាញ និង ចំណេះដឹងរបស់អ្នកចូលរួមអ្នកថ្លង់បានឡើយ។ សូមអរគុណចំពោះ
កិច្ចសហការ និង មានចំនាប់អារម្មណ៍ក្នុងគម្រោងនេះ។ ប្រសិនបើអ្នកមានសំនួរ សូមធ្វើការទំនាក់ទំនង
ជាមួយខ្ញុំ វី ថេស៊ី ។